**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទូរគមនាគមន៍កម្ពុជា**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ: ០១៤.......គ.ល

# សេចក្តីជូនដំណឹង

## ស្តីពី

## ការអញ្ជើញចូលរួមដេញថ្លៃផ្គត់ផ្គង់បរិក្ខារបច្ចេកទេសបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន សំរាប់ឆមាសទី២ ឆ្នាំ២០១៨

ទូរគមនាគមន៍កម្ពុជា សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុនក្នុងស្រុក (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា: ទូរគមនាគមន៍កម្ពុជា នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់បរិក្ខារបច្ចេកទេសបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន សំរាប់ឆមាសទី២ ឆ្នាំ២០១៨ ។

ទូរគមនាគមន៍កម្ពុជា បានរៀបចំឯកសារសំរាប់ក្រុមហ៊ុនបំពេញ ដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មនៃទូរគមនាគមន៍កម្ពុជា ដែលមានអាសយដ្ឋាន: ទូរគមនាគមន៍កម្ពុជាអគារលេខ៩៥-៩៧ ផ្លូវព្រះសីហនុ កែងនឹងផ្លូវលេខ១០៥ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨ តទៅ រៀងរាល់ម៉ោងធ្វើការ ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង ១៤:៣០នាទីរសៀល ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ១៤:៣០នាទីរសៀល ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ ។

ក្រុមហ៊ុនដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុនដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មនៃទូរគមនាគមន៍កម្ពុជា ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃសុក្រ ៣កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៨
**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**សន-ទី**

<u>សូមទាក់ទងលេខទូរស័ព្ទលេខ</u>
០២៣ ៧២ ៦៦ ៦៨

<u>ចម្លងជូន ៖</u>
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ